ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក

សេចក្តីប្រកាសព័ត៌មាន

# នាយករដ្ឋមន្ត្រីកម្ពុជា និងនូវែលសេឡង់ ពិភាក្សាអំពីការពង្រីក កិច្ចសហប្រតិបត្តិការ

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម គ្រីស្តូហ្វឺរ ឡិចសុន** នាយករដ្ឋមន្ត្រីនូវែលសេឡង់ បានសម្តែងនូវការពេញចិត្តចំពោះវឌ្ឍនភាពនៃទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏យូរអង្វែងរវាងប្រទេសទាំងពីរ ក្នុងជំនួបទ្វេភាគីនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ ក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤ និង៤៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅរដ្ឋធានីវៀងចន្ទន៍។

**ឯកឧត្តម គ្រីស្តូហ្វឺរ ឡិចសុន** បានកោតសរសើរចំពោះកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គមដ៏ឆាប់រហ័សរបស់កម្ពុជា និងសម្តែងនូវការប្តេជ្ញាចិត្តជួយគាំទ្រដល់ការអភិវឌ្ឍរបស់កម្ពុជាបន្ថែមទៀត លើវិស័យដែលនូវែលសេឡង់មានឧត្តមភាពប្រៀបធៀប។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសនូវែលសេឡង់ ដែលបានចូលរួមចំណែកដល់ដំណើរការស្វែងរកសន្តិភាព និងការរក្សាសន្តិភាពរបស់កម្ពុជា ជាពិសេសការបណ្តុះបណ្តាលបច្ចេកទេសដោះមីនក្នុងទសវត្សរ៍៩០ និងការផ្តល់ជំនួយដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា រួមទាំងក្នុងវិស័យអប់រំ កសិកម្ម ការបោសសម្អាតមីន និងការកសាងភាពធន់។

**នាយករដ្ឋមន្ត្រីទាំងពីរ**បានទទួលស្គាល់ថា ទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និងនូវែលសេឡង់ នៅមានសក្តានុពលដែលអាចពង្រីក និងបានឯកភាពជំរុញបន្ថែមនូវកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគ លើកទឹកចិត្តកិច្ចសហការធុរកិច្ចលើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងថាមពលស្អាត។ **ថ្នាក់ដឹកនាំទាំងពីរ**បានប្តេជ្ញាពង្រឹងការតភ្ជាប់រវាងប្រជាជន និងប្រជាជន និងកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ រួមទាំងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ដើម្បីសម្រេចបានគោលបំណងនេះ **នាយករដ្ឋមន្ត្រីទាំងពីរ** បានសង្កត់ធ្ងន់លើសារសំខាន់នៃការរៀបចំកិច្ចពិគ្រោះយោបល់ទៀងទាត់រវាងក្រសួងការបរទេសទាំងពីរ ដើម្បីរិះរកមធ្យោបាយនានា ក្នុងការពង្រឹង និងពង្រីក

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 34[illegible]
អ៊ីម៉ែល : mfaic@mfaic.gov.kh

កិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យ ដែលមានសក្តានុពល សម្រាប់ជាផលប្រយោជន៍ទៅវិញទៅមក។

ឆ្លៀតក្នុងឱកាសនោះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះនូវវែលសេឡង់ ដែលបានបញ្ជាក់ពីការចូលរួម **កិច្ចប្រជុំកំពូលសៀមរាប-អង្គរ ស្តីពីពិភពលោកមួយដែលគ្មានមីន** នៅថ្ងៃទី២៥-២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅខេត្តសៀមរាប។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានអញ្ជើញ**ឯកឧត្តម គ្រីស្តូហ្វឺរ ឡិចសុន** មកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា និងបានទទួលយកដោយរីករាយនូវការអញ្ជើញរបស់**ឯកឧត្តម គ្រីស្តូហ្វឺរ ឡិចសុន** ទៅបំពេញទស្សនកិច្ចផ្លូវការនៅនូវែលសេឡង់ តាមពេលវេលាសមស្រប ដ៏ឆាប់ខាងមុខ៕

ថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីវៀងចន្ទន៍ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤